KOICA

# PRESS RELEASE

**(For Immediate Release)**

## KOICAផ្តល់ថវិកា7លានដុល្លាដើម្បីលើកកម្ពស់សមត្ថភាពការអប់រំបច្ចេកវិទ្យាពត៌មានវិទ្យានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តនិងសាលាមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា

នាវេលាថ្ងៃនេះ  ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ( KOICA )បានប្រកាសផ្តល់ហិរញ្ញប្បទានចំនួន7លានដុល្លាដើម្បីលើកកម្ពស់សមត្ថភាពការអប់រំបច្ចេកវិទ្យាពត៌មានវិទ្យានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តនិងសាលាមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា។ ការប្តេជ្ញាចិត្តនេះត្រូវបានធ្វើឡើងតាមរយៈពិធីចុះហត្ថលេខារវាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ( KOICA )  និងក្រសួងអប់រំយុវជននិងកីឡានៅថ្ងៃទី  ២៤  ខែមីនា ឆ្នាំ   ២០២១ ដោយលោក Rho   Hyunjun ប្រធានកយកាប្រចាំប្រទេសកម្ពុជា និងឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា។

គម្រោងនេះផ្តោតសំខាន់លើការចូលរួមចំណែករបស់ក្រសួងអប់រំ យុវជននិងកីឡា ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេស និងគ្រូបង្រៀនក្នុងការអប់រំបច្ចេកវិទ្យាព័ត៌មានវិទ្យា នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តនិងសាលាមធ្យមសិក្សាបឋមភូមិនៅខេត្តកំពង់ចាម ព្រៃវែង តាកែវ និងកណ្តាល។

តាមរយៈគម្រោងនេះKOICA      នឹងផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិតដល់គ្រូឧទ្ទេស ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា សៀវភៅសិក្សាកុំព្យូទ័រ បំពាក់កុំព្យូទ័រ និង កែលម្អបន្ទប់សម្រាប់បង្រៀនកុំព្យូទ័រនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តនិងសាលាមធ្យមសិក្សាបឋមភូមិខាងលើ។

ក្នុងពិធីចុះហត្ថលេខានេះ លោក  Rho  Hyunjun បានមានប្រសាសន៍ថា «KOICA  សង្ឃឹមថាគម្រោងនេះនឹងធ្វើអោយប្រសើរឡើងលើការអប់រំបច្ចេកវិទ្យាព័ត៌មានវិទ្យានៅប្រទេសកម្ពុជា ក៏ដូចជាចូលរួមចំណែកគាំទ្រដល់គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍធនធានមនុស្សតាមរយៈការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

**អំពីកយកា (KOICA):** ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ( KOICA ) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩១ ក្រោមក្រសួងការបរទេសនៃសាធារណរដ្ឋកូរ៉េ       គឺជាទីភ្នាក់ងាររដ្ឋាភិបាលដែលបានផ្តល់នូវកម្មវិធីជំនួយឥត

សំណាងរបស់ប្រទេសកូរ៉េ។ កយកា (KOICA)មានគោលបំណងលើកកម្ពស់ទំនាក់ទំនងមិត្តភាពសហប្រតិបត្តិការនិងការផ្លាស់ប្តូរគ្នាទៅវិញទៅមកជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈកម្មវិធីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់បណ្តាប្រទេសទាំងនោះ។ ដើម្បីសម្រេចគោលដៅនេះ កយកា (KOICA) បានចូលរួមក្នុងគម្រោងជាច្រើនរួមទាំង កម្មវិធីគម្រោង និង កម្មវិធីផ្លាស់ប្តូរបទពិសោធន៍ក្នុងការអភិវឌ្ឍ (Development Experience Exchange Program-DEEP) កម្មវិធីអាហារូបករណ៍ មិត្តភក្តិកូរ៉េពិភពលោក (មានអ្នកស្ម័គ្រចិត្តនិងទីប្រឹក្សាកូរ៉េ) ជំនួយមនុស្សធម៌ និងជំនួយបន្ទាន់សម្រាប់គ្រោះមហន្តរាយ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) កិច្ចសហប្រតិបត្តិការពហុភាគី និងមូលនិធិទប់ស្កាត់ជំងឺឆ្លងទូទាំងពិភពលោក។

*សម្រាប់ព័ត៌មានបន្ថែមនៃសេចក្តីប្រកាសព័ត៌មាននេះ សូមទាក់ទង កញ្ញាប៉ែន វឌ្ឍីតា មន្ត្រីកម្មវិធីរបស់KOICA តាមរយៈ (+៨៥៥)០២៣ ៩៦៤ ១៥០ / thydakoica@gmail.com ។*